**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**

**តុលាការរដ្ឋប្បវេណី**

សំណុំរឿងរដ្ឋប្បវេណីលេខ ២៥៦

ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣

សាលក្រមរដ្ឋប្បវេណីលេខ ៩៤/០៤ "ច" រ.វ

ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤

# សាលក្រមរដ្ឋប្បវេណី

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តព្រះសីហនុ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤

**ចៅក្រម**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

**ដើមចោទ និងអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ**

ដើមចោទឈ្មោះ [redacted] ស្រីនិត ភេទស្រី កើតថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤ ជនជាតិខ្មែរ មានអាសយដ្ឋាន [redacted]។

លោកមេធាវី [redacted] ជាសមាជិកនៃការិយាល័យមេធាវី [redacted] និងលោក [redacted] មានទីតាំងស្ថិត [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ ។

**ចុងចម្លើយ**

ចុងចម្លើយឈ្មោះ [redacted] ស្រ៊ន (ឈ្មោះក្នុងសំបុត្រអាពាហ៍ពិពាហ៍) ឬ ឈ្មោះ [redacted] ឈឿន (ឈ្មោះក្នុងសៀវភៅគ្រួសារ) ភេទប្រុស កើតថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅភូមិ [redacted]

## អង្គហេតុ និងចំណុចវិវាទ

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

ដើមចោទទាមទារឱ្យតុលាការចេញចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម ៖



Scanned with CamScanner

១.   លែងលះពីចុងចម្លើយឈ្មោះ [redacted] ស្រ៊ន

២.   កំណត់យកដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាលើកូនប្រុសរវាងដើមចោទ និងចុងចម្លើយដែលមានឈ្មោះ [redacted] ម៉ាណា ភេទប្រុស កើតថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ។

៣.   ប្រគល់ឱ្យដើមចោទនូវទ្រព្យសម្បត្តិជាដីផ្ទះទំហំ ៥ម៉ែត្រ គុណនឹង ២០ម៉ែត្រ មានទីតាំង ស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ (តទៅហៅថា ទ្រព្យសម្បត្តិក្នុងរឿងក្តីនេះ)។

## ខ. ដំណើររឿងក្តី និងចំណុចវិវាទ

### ខ.១.   ការសង្ខេបពីរឿងក្តី

ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ ដើមចោទ និងចុងចម្លើយមានកូនចំនួន ១ នាក់ មានឈ្មោះ [redacted] ម៉ាណា ភេទប្រុស កើតថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ជាអនីតិជន ។ ដោយសារតែការរួមរស់នៅមិនចុះសម្រុង និងការរស់នៅបែកគ្នាអស់រយៈពេល ៤ ឆ្នាំ ដើមចោទដាក់ពាក្យបណ្តឹងលែងលះពីចុងចម្លើយ ដោយសុំឱ្យ តុលាការចេញសាលក្រមដូចមានសរសេរក្នុងចំណុច ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ។

### ខ.២.   អង្គហេតុដែលជាមូលដ្ឋាននៃការកំណត់ចំណុចវិវាទ

ក្នុងរឿងក្តីនេះ អង្គហេតុដែលគូភាគីទទួលស្គាល់ និងពុំមានវិវាទនឹងគ្នា មានដូចខាងក្រោម ៖

១.   ដើមចោទ និងចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

២.   ដើមចោទ និងចុងចម្លើយមានកូនប្រុសម្នាក់ឈ្មោះ [redacted] ម៉ាណា ។

៣.   ដើមចោទ និងចុងចម្លើយមិនទាមទារសោហ៊ុយចាំបាច់ដើម្បីថែរក្សាចិញ្ចឹមកូននោះទេ ប្រសិនបើ តុលាការសម្រេចអំពីអំណាចមេបាឱ្យភាគីណាម្ខាង ។

៤.   ដើមចោទ និងចុងចម្លើយថា ពួកខ្លួនមានទ្រព្យសម្បត្តិដី និងផ្ទះ ៥ម៉ែត្រ គុណនឹង ២០ម៉ែត្រ ស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

### ខ.៣. ចំណុចវិវាទ

ចំណុចវិវាទនៃរឿងក្តីមានដូចខាងក្រោម ៖

១.   តើទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយ ពិតជាបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានដែរ ឬទេ ?



Scanned with CamScanner

២. តើការប្រគល់កូនឱ្យដើមចោទ ឬចុងចម្លើយមួយណាអាចមានផលប្រយោជន៍ដល់កូនច្រើនជាង ?

៣. តើដើមចោទ និងចុងចម្លើយមានទ្រព្យសម្បត្តិរួមតាមការទាមទារដែរឬទេ? ប្រសិនបើជាទ្រព្យសម្បត្តិរួមនោះជារបស់ដើមចោទ និងចុងចម្លើយ តើតុលាការគួរបែងចែកយ៉ាងដូចម្តេចដែរ ?

## ខ.៤ ការអះអាងរបស់គូភាគីនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

### ខ.៤.១ ការអះអាងរបស់ដើមចោទ

ខ្លួននៅតែមានឆន្ទៈក្នុងការលែងលះជាមួយចុងចម្លើយដដែល ដោយសារតែមូលហេតុដូចមានសរសេរនៅក្នុងពាក្យបណ្តឹង ។ មូលហេតុនៃការលែងលះនេះគឺមិនមែនដោយសារចុងចម្លើយប្រើអំពើហិង្សានោះទេ គឺដោយសារតែការអស់មនោសញ្ចេតនា និងបញ្ហាដែលខ្លួនមិនពេញចិត្តឱ្យក្មួយរបស់ចុងចម្លើយមករស់នៅក្នុងផ្ទះជាមួយ ព្រមទាំងដោយសារតែចុងចម្លើយមិនដែលឱ្យលុយប្រាក់ខែនោះមកឱ្យខ្លួនទុក ។

ចំពោះកូនប្រុសឈ្មោះ [redacted] ម៉ាណា សព្វថ្ងៃរស់នៅជាមួយខ្លួន ។ ខ្លួននៅជាមួយកូនប្រុសតាំងពីកូនប្រុសកើតមកម្ល៉េះ ។ ខ្លួនធ្លាប់រស់នៅបែកពីកូនប្រុស នៅអំឡុងពេលកូវីត ពេលនោះកូនទៅរស់នៅជាមួយចុងចម្លើយជាឪពុក ។ នៅឆ្នាំ២០២៣ ខ្លួនឈប់ធ្វើការ ទើបកូនមករស់នៅជាមួយខ្លួនវិញដល់សព្វថ្ងៃ ។ ខ្លួនបង់ថ្លៃសាលាកូនក្នុង ១ ខែ តម្លៃ ១៥០ (មួយរយហាសិប) ដុល្លារ ទៅ ១៦០ (មួយរយហុកសិប) ដុល្លារ ។ បច្ចុប្បន្នខ្លួនមិនទាន់ចូលធ្វើការងារវិញទេ តែខ្លួនមានប្រាក់ចំណូលពីការចងការប្រាក់ឱ្យគេ និងប្រាក់ថ្លៃឈ្នួលផ្ទះ ។ ខ្លួននឹងចូលធ្វើការងារវិញ នៅខែក្រោយខាងផ្នែកបម្រើសេវាកម្មនៅកាស៊ីណូ [redacted] ខេត្តព្រះសីហនុ ។ ខ្លួននឹងធ្វើការនៅពេលយប់ ។ កូនរបស់ខ្លួនរៀននៅពេលថ្ងៃ ។ ពេលខ្លួនទៅធ្វើការ គឺមានអ្នកជិតខាងជួយមើល ហើយកូនខ្លួនធំល្មម និងអាចមើលថែខ្លួនគាត់បានខ្លះហើយ ។ ចំពោះការសម្រេចអំពីសិទ្ធិអំណាចមេបាលើកូន ខ្លួនសុំឱ្យតុលាការសួរយោបល់ពីកូនថា គាត់ចង់រស់នៅជាមួយខ្លួន ឬចុងចម្លើយជាឪពុក ។

ចំពោះទ្រព្យសម្បត្តិក្នុងរឿងក្តីនេះ ខ្លួនសូមឱ្យតុលាការធ្វើការសម្រេចទៅតាមច្បាប់ ។ ខ្លួនពុំមានឯកសារផ្សេងទៀតដើម្បីបញ្ជាក់អំពីអត្ថិភាពនៃទ្រព្យសម្បត្តិក្នុងរឿងក្តីនេះទេ ។

### ខ.៤.២ ការអះអាងរបស់ចុងចម្លើយ

ខ្លួនមិនធ្លាប់ប្រើប្រាស់អំពើហិង្សាទៅលើចុងចម្លើយទេ ។ ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាឱ្យក្មួយរបស់ខ្លួនមករស់នៅក្នុងផ្ទះជាមួយមែន ខណៈពេលដែលប្រពន្ធខ្លួនមិនព្រម ឬមិនសប្បាយចិត្ត ។ ខ្លួនបានឱ្យប្រាក់ខែរបស់ខ្លួនទៅឱ្យដើមចោទ ប៉ុន្តែដើមចោទមិនព្រមយកនោះទេ ខ្លួនមានក្មួយដែលដឹងឮរឿងនេះ ។ ដោយសារតែខ្លួនឃើញថា ដើមចោទនៅតែចង់លែងលះជាមួយនឹងខ្លួន ហេតុនេះ ខ្លួនយល់ព្រមលែងលះជាមួយដើមចោទដែរ ។



Scanned with CamScanner

ចំពោះកូនប្រុសឈ្មោះ [redacted] ម៉ាណា ខ្លួនធ្លាប់មើលថែតែម្នាក់ឯងនៅអំឡុងឆ្នាំ២០២១ ដល់ឆ្នាំ ២០២២ ។ សព្វថ្ងៃខ្លួនធ្វើការងារជាកូនកាំបិត (ចុងភៅ) និងបានប្រាក់ខែក្នុងមួយខែចំនួន ៤០០ (បួនរយ) ដុល្លារ ។ ចំពោះការសម្រេចអំពីសិទ្ធិអំណាចមេបាលើកូន ខ្លួនសុំឱ្យតុលាការសួរយោបល់ពីកូនរបស់ខ្លួនថា គាត់ចង់រស់នៅជាមួយខ្លួន ឬដើមចោទជាម្តាយ ។ ខ្លួនឯកភាពនឹងបំណងរបស់កូន ។

ចំពោះ ទ្រព្យសម្បត្តិក្នុងរឿងក្តីនេះ ខ្លួនសូមឱ្យតុលាការធ្វើការសម្រេចទៅតាមច្បាប់ ។

### ខ.៤.៣ ការអះអាងរបស់សាក្សី

នៅក្នុងដំណាក់កាលនៃការទាញហេតុផលហេតុដោយផ្ទាល់មាត់ ឈ្មោះ [redacted] ម៉ាណា ដែលជាកូនរបស់ដើមចោទ និងចុងចម្លើយបានឆ្លើយថា ៖ ខ្លួនមានអាយុ ១១ ឆ្នាំ ហើយ ។ ខ្លួនស្រលាញ់ឪពុកម្តាយដូចគ្នា ប៉ុន្តែ ខ្លួនចង់រស់នៅជាមួយនឹងម្តាយខ្លួនជាងឪពុក ។ ពេលម្តាយខ្លួនទៅធ្វើការងារនៅពេលយប់នោះ ខ្លួនអាចគេងម្នាក់ឯងបាន ។

## សំអាងហេតុ

### ក. ការវិនិច្ឆ័យអំពីការលែងលះ

១. តាមការពិនិត្យសំបុត្រអាពាហ៍ពិពាហ៍លេខ ១២ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ព្រែកជំបូក តុលាការអាចជឿជាក់ថា ដើមចោទឈ្មោះ [redacted] ស្រីនិត និងចុងចម្លើយឈ្មោះ [redacted] ឈឿន ពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់មែន ដែលត្រង់ចំណុចនេះអាចបញ្ជាក់បានថាអ្នកទាំងពីរគឺពិតជាប្តីប្រពន្ធស្របច្បាប់ ស្របតាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណីមែន ។

២. ផ្អែកតាមការអះអាងរបស់គូភាគី តុលាការពិនិត្យឃើញថា ដោយសារតែការអស់មនោសញ្ចេតនា និងបញ្ហានៃការរស់នៅមិនចុះសម្រុងគ្នា ដើមចោទ និងចុងចម្លើយបានបង្ហាញឆន្ទៈឯកភាពគ្នាក្នុងការលែងលះគ្នាចំពោះមុខតុលាការ ដែលនេះជាហេតុនាំឱ្យតុលាការអាចទទួលស្គាល់ថា ចំណងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិសាធន៍ឡើងវិញបាន ។ ហេតុនេះ តុលាការយល់ឃើញថា ការទាមទារលែងលះរបស់ដើមចោទមានមូលហេតុត្រឹមត្រូវស្របតាមចំណុច ង កថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ដែលតុលាការគប្បីសម្រេចឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នា ។

### ខ. ការវិនិច្ឆ័យអំពីសិទ្ធិអំណាចមេបា

១. ផ្អែកតាមសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់លេខ១ តុលាការអាចទទួលស្គាល់ថា ឈ្មោះ [redacted] ម៉ាណា កើតនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ដែលជាអនីតិជន គឺពិតជាកូនប្រុសរបស់ដើមចោទ និងចុងចម្លើយប្រាកដមែន ។



Scanned with CamScanner

២. ចំពោះបញ្ហាសិទ្ធិអំណាចមេបាលើកូនប្រុសនោះ ដើមចោទ និងចុងចម្លើយបានឯកភាពគ្នាថា នឹងគោរពតាមការសម្រេចចិត្តរបស់កូនប្រុសក្នុងការជ្រើសរើសដើមចោទ ឬចុងចម្លើយធ្វើជាអ្នកមានសិទ្ធិអំណាចមេបា ដែលនេះអាចចាត់ទុកថា ជាការពិភាក្សាដែលមានការឯកភាពគ្នាមួយរវាងដើមចោទ និងចុងចម្លើយ ហើយតុលាការគប្បីយកចំណុចនេះមកពិចារណាផងដែរ ព្រោះថា កូនប្រុសរបស់គូភាគីមានអាយុ ១១ ឆ្នាំ ដែលល្មមអាចបង្ហាញពីបំណង ឬឆន្ទៈរបស់គាត់បានដែរហើយ ។ បើតាមចម្លើយរបស់ឈ្មោះ [redacted] ម៉ាណា ដែលជាកូនរបស់គូភាគី ឈ្មោះ [redacted] ម៉ាណា ឆ្លើយថា "ខ្លួនចង់រស់នៅជាមួយនឹងម្តាយខ្លួនជាងឪពុក" ។

៣. ការបង្ហាញឆន្ទៈរបស់កូនខាងលើនេះ តុលាការយល់ឃើញថា គឺជាផ្នែកមួយដ៏សំខាន់ ដើម្បីឱ្យតុលាការយកមកពិចារណាក្នុងការសម្រេចអំពីអ្នកមានអំណាចមេបា នេះបើយោងតាមមាត្រា ២២ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។ បន្ថែមពីនេះ តុលាការយល់ឃើញថា ការប្រគល់សិទ្ធិអំណាចមេបាតាមឆន្ទៈរបស់កូននេះក៏មានប្រយោជន៍ដល់កូនប្រុសនេះ បើពិចារណាចំណុចនេះជាមួយនឹងលទ្ធភាពចិញ្ចឹមកូនរបស់ដើមចោទ និងទំនាក់ទំនងនៃភាពស្និទ្ធស្នាលរវាងកូននឹងម្តាយ ។ ក្នុងរឿងនេះ តុលាការពិនិត្យឃើញថា ដើមចោទដែលជាម្តាយគឺមានការងារ និងប្រាក់ចំណូលដែលអាចចិញ្ចឹមកូនប្រុសនេះបានដែរ ហើយបើតាមការរស់នៅកន្លងមករវាងកូន និងម្តាយ ទោះបីជាម្តាយត្រូវទៅធ្វើការងារពេលយប់ក៏ដោយ ក៏កូនប្រុសនោះអាចមើលថែខ្លួនឯង និងមានអ្នកជិតខាងជួយមើលដោយមិនមានបញ្ហាអ្វីនោះទេ ។ ជាចុងក្រោយគឺឆន្ទៈរបស់កូនប្រុសផ្ទាល់ដែលចង់រស់នៅជាមួយម្តាយ ។ ស្ថានភាពទាំងនេះធ្វើឱ្យតុលាការយល់ឃើញថា ដើមចោទគឺមានទំនាក់ទំនងស្និទ្ធស្នាល ឬល្អជាមួយកូនប្រុសជាងឪពុក និងមានលទ្ធភាពចិញ្ចឹម និងមើលថែកូននោះបានល្អផងដែរ ។ ហេតុនេះ តុលាការយល់ឃើញថា គប្បីប្រគល់សិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ម៉ាណា ឱ្យដើមចោទដែលជាម្តាយតាមឆន្ទៈរបស់កូនប្រុស យោងតាមកថាខណ្ឌទី ៣ មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ។

## គ. ការវិនិច្ឆ័យអំពីទ្រព្យសម្បត្តិ

១. ផ្អែកតាមភស្តុតាងជាឯកសាររបស់ដើមចោទ តុលាការមិនអាចទទួលស្គាល់ថា ដើមចោទ និងចុងចម្លើយជាម្ចាស់កម្មសិទ្ធិករលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិក្នុងរឿងក្តីនេះទេ ដោយហេតុថា ដើមចោទ និងចុងចម្លើយមានតែភស្តុតាងជាកិច្ចសន្យាលក់ផ្តាច់ដែលបញ្ជាក់បានត្រឹមថា ដើមចោទ និងចុងចម្លើយបានទិញដីមួយកន្លែងពីអ្នកលក់ ។ ចំពោះភស្តុតាងរបស់ដើមចោទនេះ តុលាការយល់ឃើញថា វាមិនគ្រប់គ្រាន់បង្ហាញពីសិទ្ធិកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លើដីដែលជាកម្មវត្ថុនៃការលក់ទិញនោះទេ ព្រោះកិច្ចសន្យាលក់ទិញមិនត្រូវបានធ្វើឡើងដោយមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ឬត្រឹមត្រូវតាមនីតិវិធីច្បាប់ ។ ហេតុដូច្នេះ តុលាការគប្បីសម្រេចច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ ។



Scanned with CamScanner

ប្រាក់ប្រដាប់ក្តីគប្បីជាបន្ទុករបស់ចុងចម្លើយ ដោយយោងតាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១. លែងលះដើមចោទឈ្មោះ [redacted] ស្រីនិត និងចុងចម្លើយឈ្មោះ [redacted] ស្រ៊ន ។

២. កំណត់ថា ដើមចោទឈ្មោះ [redacted] ស្រីនិត ជាម្តាយ ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ម៉ាណា កើតនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ។

៣. ច្រានចោលការទាមទាររបស់ដើមចោទដែលសុំឱ្យ "ប្រគល់ឱ្យដើមចោទនូវទ្រព្យសម្បត្តិជា ដីផ្ទះទំហំ ៥ ម៉ែត្រ គុណនឹង ២០ម៉ែត្រ មានទីតាំង ស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ" ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ ។

ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងនៅក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

ថ្ងៃព្រហស្បត្តិ៍ ១១រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ខេត្តព្រះសីហនុ, ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤

**ចៅក្រម**

ហត្ថលេខា និងត្រា

[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បត្តិ៍ ១១រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ខេត្តព្រះសីហនុ, ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner